**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍
# កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែឧសភា ឆ្នាំ២០២២
# ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី

១)- **ថ្ងៃ ខែ ឆ្នាំ៖** នាព្រឹកថ្ងៃអង្គារ ១កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។

២)- **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣)- ប្រធាន និងសមាសភាពចូលរួម ៖

- ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ឯកឧត្តម លោកជំទាវ ជាអនុប្រធាន ទីប្រឹក្សា នាយក-នាយករងខុទ្ទកាល័យ អគ្គលេខាធិការ អគ្គលេខាធិការរង ជំនួយការ ប្រធាននាយកដ្ឋាន នៅក្នុងសាលប្រជុំ "ខ" ។
- លោក អ្នកស្រី អ្នកនាងកញ្ញា អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុការិយាល័យ ព្រមទាំងមន្ត្រីនៃ អ.ជ.ប.ជ.អ ចូលរួមតាមបណ្តាញវីដេអូ កម្មវិធី Zoom។

៤)- របៀបវារៈ ៖

- បទបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលសកម្មភាពការងារប្រចាំខែមេសា និងទិសដៅការងារខែឧសភា ឆ្នាំ ២០២២ ដោយឯកឧត្តម **ឈឹម ឃិនដារ៉េត**។
- បទបង្ហាញ ស្តីពីលទ្ធផលនៃការប៉ាន់ស្មាន ថ្នាក់ ក្រោមជាតិ និងការឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ ដោយ ឯកឧត្តម **ទា ផល្លា**។
- មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី
- កិច្ចការផ្សេងៗ។

៥)- លទ្ធផល ៖

១). **បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

ក- សកម្មភាពការងារដែលសម្រេចបាន ៖

- បានប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ពិនិត្យវឌ្ឍនភាពការងារ និងដាក់ទិសដៅ។
- បានរៀបសិក្ខាសាលាប្រចាំតំបន់ ស្តីពីអំពើហឹង្សាទាក់ទងទៅនឹងយេនឌ័រ និងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- បានរៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិសក្នុងការបញ្ចូលការងារអេដស៍ទៅក្នុងផែនការ៣ឆ្នាំរំកិល ដល់ថ្នាក់ឃុំ សង្កាត់។
- បានរៀបចំវគ្គបណ្តុះបណ្តាលឧបករណ៍តាមដាន វាយតម្លៃសជណ២១៣។
- បានរៀបចំវគ្គបណ្តុះបណ្តាលសមាហរណកម្មកម្មវិធីអេដស៍ក្នុងផែនការអភិវឌ្ឍ ឃុំ សង្កាត់។

ខ- បញ្ហាប្រឈម ៖

ការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅមានកំរិត

គ- **ទិសដៅអនុវត្តបន្ត៖**

- បន្តអនុវត្តសកម្មភាពតាមផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. ឆ្នាំ២០២២។
- បន្តចុះបណ្តុះបណ្តាលការត្រួតពិនិត្យការអនុវត្តសជណ២១៣ តាមបណ្តារាជធានី ខេត្តគោលដៅ។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៦ ថ្ងៃទី២០ ខែមិថុនា ។
- រៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ នៅទីស្តីការគណៈរដ្ឋមន្ត្រី។
- ប្រមូលជាតុចូលពីក្រសួងសុខាភិបាល។
- រៀបចំសេចក្តីព្រាងវាយតម្លៃលក្ខណៈសម្បត្តិគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍។

២). **បទបង្ហាញ ស្តីពីលទ្ធផលនៃការប៉ាន់ស្មាន ថ្នាក់ ក្រោមជាតិ និងការឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ ដោយ ឯកឧត្តម ឆា ផលា**

- ដំណាក់កាលឆ្លងថ្មី អំឡុងពេលតិចជាង១២ខែ មានលក្ខណៈស្រួចស្រាវខ្លាំង ហើយក្នុងរយៈពេលប្រហែល ៣-៦ខែដំបូង មេរោគក្នុងកំហាប់ឈាមប្រហែលលើស ១លាន ដែលនាំអោយប្រឈមនឹងការចម្លងខ្ពស់។
- ករណីមានជំងឺរ៉ាំរ៉ៃ គឺការផ្ទុកមេរោគលើសពី១២ខែ។
- នៅក្នុងកម្មវិធីថែទាំនិងព្យាបាល អ្នកដែលបានធ្វើតេស្ត និងមិនបានធ្វើតេស្តមានចំនួនតិចជាងអ្នកជំងឺសរុបទាំងអស់។
- ការបញ្ចូលទិន្នន័យ ( Data input ) Spectrums ART នៅតាមខេត្តនានា ដើម្បីធ្វើការវាយតម្លៃក្នុងការផ្ទៀងផ្ទាត់តួលេខពីកន្លែងមួយទៅកន្លែងមួយ ផ្អែកលើការធ្វើរោគវិនិច្ឆ័យលើអ្នកផ្ទុកមេរោគ លើប្រជាជនគន្លឹះតេស្តដែលបានបញ្ជាក់ ( test confirm )។
- លទ្ធផលនៃការប៉ាន់ស្មានបង្ហាញពីការចល័តរបស់អ្នកផ្ទុកមេរោគអេដស៍មួយចំនួនទៅទទួលការព្យាបាលឆ្លងខេត្ត។ ការនេះបង្កការលំបាកក្នុងការតាមរកក្នុងករណីអ្នកជំងឺបោះបង់ការព្យាបាល។ ដូចេនះរាជធានីខេត្តនីមួយៗ មិនត្រឹមតែទទួលខុសត្រូវលើការសម្របសម្រួលសេវាថែទាំ ព្យាបាល ដល់អ្នកផ្ទុកមេរោគ

អេដស៍ដែលទទួលសេវាក្នុងរាជធានីខេត្តផ្ទាល់ខ្លួនទេ គឺត្រូវជួយជំរុញ និងតាមរកអ្នកផ្ទុកមេរោគអេដស៍ដែលទទួលសេវាព្យាបាលនៅក្រៅរាជធានី ខេត្តខ្លួនផងដែរ ពិសេសជួយតាមរកអ្នកបោះបង់។

- ការបញ្ចូលទិន្នន័យអ្នករស់នៅជាមួយមេរោគអេដស៍ ទៅក្នុងប្រព័ន្ធមានការលំបាកខ្លាំងណាស់ ដោយសារពួកគាត់មានការផ្លាស់ប្តូរទីតាំងនៃការរស់នៅជាញឹកញាប់ បោះបង់សេវាព្យាបាល អត្រាស្លាប់ និងអ្នកនៅក្រៅប្រព័ន្ធ។
- ខេត្តដែលមានវិធានការបង្ការក្នុង *គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (Fast Track City) បានដាក់ចំណាត់ថ្នាក់ ដូចជា ខេត្តបាត់ដំបងលេខ១ ខេត្តបន្ទាយមានជ័យលេខ២ រាជធានីភ្នំពេញលេខ៣ និងខេត្តសៀមរាបលេខ៤។
- នៅឆ្នាំ ២០២២នេះ ខេត្ត បាត់ដំបង ខេត្តកំពត កោះកុង បានសម្រេចគោលដៅរួចហើយ។
- ត្រូវត្រួតពិនិត្យតួលេខឡើងវិញឱ្យបានញឹកញាប់ ដើម្បីឱ្យការប៉ាន់ប្រម៉ាណតួលេខវាកាន់តែជៀកទៅនឹងលទ្ធផលជាក់ស្តែង។
- នៅមានបញ្ហាតែ ៩៥ទី១ គឺធ្វើយ៉ាងណាទប់មិនឱ្យឆ្លង និងស្វែងរកករណីដែលបាត់ ដើម្បីដាក់ចូលក្នុងប្រព័ន្ធ។
- តួនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គឺទទួលខុសត្រូវធំទូលាយ និងពហុវិស័យ មានភារកិច្ចត្រួតពិនិត្យ វាយតម្លៃ សម្របសម្រួល និងណែនាំអនុវត្តផែនការយុទ្ធសាស្ត្រជាតិ។
- ការធ្វើ strategy working groups នឹងជំរុញប្រសិទ្ធភាពនៃការសម្របសម្រួលការអនុវត្តផែនការសកម្មភាពឆ្ពោះទៅសម្រេចគោលដៅកាន់តែប្រសើរឡើង និងមិនខ្ជះខ្ជាយពេលវេលា។
- strategy working group ទី១ មាននាទីត្រូវពិនិត្យឡើងវិញលើការផ្សព្វផ្សាយសារអប់រំ ស្តីពីវិធានការបង្ការការចំលងមេរោគអេដស៍ ពិសេសសារជំរុញការប្រើ PreP សម្រាប់ក្រុមបុរសរួមភេទជាមួយបុរស។ សារអប់រំគួរត្រូវផ្តោតលើការបង្ហាញហានីភ័យនៃការឆ្លងមេរោគអេដស៍ ផលវិបាកនៃការឆ្លងមេរោគអេដស៍លើសុខភាព ការរំខានដល់ប្រសិទ្ធភាពបំពេញការងារ ការរំខានដល់លទ្ធភាពបត់បែនក្នុងការបំពេញការងារដូចជាការលំបាកចល័តទីតាំងការងារទៅឆ្ងាយពីសេវាសុខភាពនៅក្រោយពេលឆ្លងមេរោគអេដស៍ ផលប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ ។ល។ ជាជាងសារដែលផ្តោតតែលើការសប្បាយៗ។

## ៣). មតិចូលរួម ៖

### ១- ឯកឧត្តម ស៊ឹម គឹមសាន

- តួលេខត្រូវឱ្យច្បាស់មុនធ្វើបទបង្ហាញ ពិសេស គឺ NCHADS ចំពោះអ្នកដែលបានទទួលសេវាហើយមានទិន្នន័យត្រឹមត្រូវ ប៉ុន្តែចំពោះករណីថ្មីដែលមានការពិបាកក្នុងការគ្រប់គ្រង។
- ពង្រឹងគណៈកម្មាធិការអេដស៍ខេត្ត ក្រុង ស្រុក ឃុំសង្កាត់ដែលជាកត្តាសំខាន់ ប៉ុន្តែថវិកាជាតិសម្រាប់កម្មវិធីអេដស៍នាប៉ុន្មានឆ្នាំនៃវិបត្តិកូវីដនេះបានកាត់ទាំងស្រុង។

### ២- ឯកឧត្តម គង់ រដ្ឋា

- អគ្គលេខាធិការដ្ឋាន ត្រូវមកធ្វើការជាប្រក្រតីឡើងវិញ គឺព្រឹក និងល្ងាច ដោយចាប់អនុវត្តពីថ្ងៃទី០៧ ខែមិថុនានេះតទៅ ព្រមទាំងយកវត្តមានឱ្យបានទៀងទាត់ ដាក់ជូនខុទ្ទកាល័យនៅម៉ោង១១។
- ពង្រឹងវិន័យ និងការទទួលខុសត្រូវឱ្យមានប្រសិទ្ធភាព។
- គ្រប់ការងារទាំងអស់ត្រូវគោរពទៅតាមឋានានុក្រម។

- នាយកដ្ឋានបច្ចេកទេស រាល់ពេលទៅប្រជុំជាមួយដៃគូរនានា (ក្រៅអង្គភាព) ចាំបាច់មានប្រធានបទ និងឯកសារពាក់ព័ន្ធ ត្រូវឆ្លងយោបល់ឯកភាពរបស់*អគ្គលេខាធិការ*។
- គ្រប់ឯកសារទាក់ទងនឹងការងារបច្ចេកទេស (ប្រជុំថ្នាក់ដឹកនាំចង្អៀត) *អគ្គលេខាធិការ* ចាំបាច់ត្រូវឆ្លងយោបល់ឯកភាពរបស់ឯកឧត្តម **ឆា ឥលា** អនុប្រធានទទួលបន្ទុកការងារបច្ចេកទេស។
- អគ្គលេខាធិការ ត្រូវសុំពិគ្រោះយោបល់ពីឯ.ឧ. អនុប្រធានទទួលបន្ទុកបច្ចេកទេស លើប្រធានបទដែលត្រូវជួបជាមួយដៃគូផ្សេងៗ
- *ខុទ្ទកាល័យ និងអគ្គលេខាធិការដ្ឋាន* ត្រូវសហការគ្នា ដើម្បីត្រៀមរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២។ អគ្គលេខាធិការ ត្រូវរកពេលវេលាសមស្របដើម្បីរៀបចំកិច្ចប្រជុំវាយតម្លៃលក្ខណៈសម្បត្តិតាមក្រសួង ស្ថាប័ន និងប្រជុំគណៈកម្មការគ្រប់គ្រងពិធីការនៃកិច្ចប្រជុំពេញអង្គឱ្យបានមុនថ្ងៃទី១០ ខែមិថុនា។
- អនុប្រធានទាំងអស់ត្រូវចុះជួយពង្រឹងគណៈកម្មាធិការអេដស៍តាមក្រសួង ស្ថាប័ន ដែលខ្លួនទទួលបន្ទុក។

## ៤). មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី

ឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

- ចាប់ពីថ្ងៃទី៧ ខែមិថុនា ត្រូវមកធ្វើការធម្មតាឡើងវិញ (ព្រឹក និងល្ងាច)
- ត្រូវពិនិត្យអំពីកម្មវិធីមូលនិធិសកលទាំងមូល ដែលយើងទទួលខុសត្រូវ និងសម្របសម្រួលអនុវត្តប្រកបដោយប្រសិទ្ធិភាព។
- អគ្គលេខាធិការដ្ឋាន ត្រូវអនុវត្ត និងតម្រង់ទិសដៅ ***ស្តីពីការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ*** (Mild term review) នៃ***ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥។***
- ការរៀបចំកិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ លើកទី១ ដែលមានការចូលរួមគ្រប់ក្រសួង ស្ថាប័ន និងបានផ្តល់របាយការណ៍គ្រប់ៗគ្នា ព្រមទាំងអនុវត្តសកម្មភាពតាមការណែនាំរបស់ អ.ជ.ប.ជ.អ។
- ថ្នាក់ដឹកនាំ សូមពិនិត្យមើល Global Fund Strategy (2023-2028) មាននៅក្នុងគេហទំព័រ មានសារៈប្រយោជន៍ ដើម្បីលើកផែនការសកម្មភាព និងស្នើសុំថវិកាមូលនិធិសកលអោយស្របតាមទិសដៅរបស់គេដើម្បីជានាភាពជោគជ័យខ្ពស់ក្នុងការស្នើសុំថវិកា។
- ត្រូវឱ្យមានការចូលរួមមតិរបស់អង្គការសង្គមស៊ីវិល ហើយជំរុញឱ្យគាត់មកប្រជុំក្នុងនាមជាអ្នកតំណាងរបស់សហគមន៍ ពិតប្រាកដ។
- ត្រូវសិក្សាចំនុចចន្លោះប្រហោងដើម្បីព្យាយាមជំរុញអន្តរាគមន៍យើងអោយបានស៊ីសង្វាក់គ្នានឹង Targets របស់ UNAIDS 2025 ៩៥-៩៥-៩៥ និង៣០-៨០-៦០។
- គោលដៅដែលពាក់ព័ន្ធនឹងសហគមន៍ក្នុងការអន្តរាគមន៍ឆ្លើយតបនឹងមេរោគអេដស៍ មានដូចជា៖
    - ៣០% testing treatment
    - ៨០% HIV prevention
    - ៦០% program to support the achievement of societal enablers.
- យើងត្រូវជម្រុញការអនុវត្តអោយសម្រេចគោលដៅ ៩៥-៩៥-៩៥ ពិសេស៩៥ទី១

- ➢ ៩៥% ទី១ ស្ត្រីដែលពេញវ័យ ដែលមានផ្ទុកមេរោគអេដស៍ ឬដល់វ័យគ្រប់ការ ឱ្យគាត់ទទួលបានសេវា ដែលគាត់ត្រូវការ (ក្រសួងកិច្ចការនារី សុខាភិបាល សង្គមកិច្ច ថ្នាក់ក្រោមជាតិ)
- ➢ ៩៥% ទី២ លើស្ត្រីមានផ្ទៃពោះ និងបំបៅកូនដោយទឹកដោះម្តាយ ដែលមានផ្ទុកមេរោគអេដស៍ (PLHIV) គឺត្រូវមាន Viral Suppression ក្រសួងសុខាភិបាលជាអ្នកអនុវត្ត (ដាក់ក្នុងសេចក្តីសម្រេចកិច្ចប្រជុំពេញអង្គលើកទី១)
- ➢ ៩៥% ទី៣ លើកុមារដែលមានផ្ទុកមេរោគអេដស៍ (PLHIV) ត្រូវធ្វើតេស្ត ដោយក្រសួងសុខាភិបាល (ដាក់ក្នុងសេចក្តីសម្រេចកិច្ចប្រជុំពេញអង្គលើកទី១)
- ➢ ៩៥% ទី៤ ក្រុមប្រឈមខ្ពស់ ដូចជា បុរសរួមភេទជាមួយបុរស អ្នកប្តូរភេទ ស្ត្រីក្នុងសេវាកម្សាន្ត ឱ្យពួកគាត់បានទទួលពីវិធានការបង្ការ។

- ស្នើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់ថវិកាបន្ថែមចំនួន៦០លានរៀលក្នុងមួយខេត្ត សម្រាប់ដំណើរការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ បន្ថែម១០ខេត្តទៀត ។
- ឯកឧត្តមអគ្គលេខាធិការ ត្រៀមរៀបចំកម្មវិធីបទសម្ភាសន៍របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ជាមួយទូរទស្សន៍ក្រោយកិច្ចប្រជុំពេញអង្គ ដើម្បីលើកអំពីការរាលដាលនៃមេរោគអេដស៍ និងការកង្វល់របស់ អ.ជ.ប.ជ.អ ។

## ការផ្តល់អនុសាសន៍

១- អបអរសាទរចំពោះលទ្ធផលអង្គប្រជុំក្រុមប្រឹក្សាបច្ចេកទេស។

២- អគ្គលេខាធិការ ពង្រាងនូវរបៀបវារៈនៃអង្គប្រជុំក្រុមប្រឹក្សាបច្ចេកទេស ជូនកិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀតពិនិត្យ និងផ្តល់មតិ មុនកិច្ចប្រជុំប្រចាំខែ។

៣- អគ្គលេខាធិការ ដឹកនាំប្រជុំក្រុមប្រឹក្សាបច្ចេកទេស ដោយយោងតាមរបៀបវារៈដែលបានដាក់ជូន និងសម្រេចក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត។

៤- ឯកភាពជូន ឯកឧត្តម **ឆា ផលា** ដឹកនាំក្រុមការងារពង្រាងសេចក្តីសម្រេចនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២ លើចំនុចសំខាន់ៗដូចខាងក្រោម ៖

- ការរុករកអ្នកមិនទាន់ទទួលសេវាការព្យាបាល (១២,០០០)
- បង្កើនសកម្មភាពបង្ការក្នុងចំណោមប្រជាជនគន្លឹះ ដូចជា MSM, EW, TG និងPWID ។
- បង្កើនកម្មវិធីបង្ការដោយប្រើ PreP។
- លើកទឹកចិត្ត ឬរំឭកដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន ឱ្យដំណើរការ លើកផែនការសកម្មភាពតាមអាណត្តិ និងសំណើសុំថវិកា។

៥- ***អគ្គលេខាធិការដ្ឋាន និងខុទ្ទកាល័យ*** ឱ្យសហការគ្នាយ៉ាងជិតស្និត ដើម្បីត្រៀមរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២ ឱ្យបានជោគជ័យ។

៦- ចាត់តាំង ឯកឧត្តម **ហោ ម៉ុនឡេខ** ឱ្យដឹកនាំក្រុមការងារសិក្សាអំពីប្រធានបទ និងវិធីសាស្ត្រនៃការទប់ស្កាត់ ការបង្ការការរីករាលដាលនៃជំងឺអេដស៍ ជាពិសេសទាក់ទងនឹង MSM, EW, TG និងPWID។

៧- កិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត ត្រូវធ្វើនៅថ្ងៃទី១៥ ខែមិថុនា ដើម្បីពិនិត្យលើពង្រាងសេចក្តីសម្រេច របៀបវារៈកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស និងរបៀបវារៈកិច្ចប្រជុំពេញអង្គ។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការអនុវត្តការងារឱ្យចំទិសដៅ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមយន្តការយុទ្ធសាស្ត្រនីមួយៗឱ្យកាន់តែប្រសើរឡើង។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:៥៨នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២
**អ្នកធ្វើរបាយការណ៍**

ស៊ុត_ថនដាន់

**បានឃើញ និងឯកភាព**
**ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ**

អៀង_មូលី